ទស្សនាវដ្ដី
សម្លេងខ្មែរនៅបរទេស

# ស្ដេចសីហនុនិងសង្គ្រាមប្រល័យពូជសាសន៍

ដោយ សុទ្ធ-ប៉ូលិន ⋆ ថ្ងៃទី២១ មិថុនា ២០០៥

ក្នុងបច្ចុប្បន្ននេះ ដែលតុលាការអន្តរជាតិកំពុងរៀបចំកាត់ទោសខ្មែរក្រហមពីបទប្រល័យពូជសាសន៍... ស្ដេចសីហនុស្រាប់តែរត់ទៅពួនសម្ងំសារជាថ្មីម្ដងទៀតនៅប៉េកាំង ។ ក៏ប៉ុន្តែទោះបីសម្ដេចខំប្រឹងប្រែងរត់ចុះរត់ឡើងយ៉ាងណាក្ដី គាត់មិនអាចលាក់ឧក្រិដ្ឋកម្មប៉ុនភ្នំរបស់គាត់បានទេ, ដោយហេតុថា គឺគាត់នោះហើយជាដើមចមនៃសង្គ្រាមប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា ។

សូមអានអត្ថបទមួយ ជា«ឯកសារប្រវត្តិសាស្ត្រ» ដែលសម្ដេចខ្លួនឯងបានរក្សាទុកនៅក្នុង«វែបសាយ»របស់ទ្រង់ ៖

«អេភី, ភ្នំពេញ, ថ្ងៃទី១ ឧសភា ១៩៧០

«ដោយ Max Nasih

អ្នកនាំពាក្យយោធាខ្មែរ, លោកវរសេនិយទោ អំ-រ៉ុង បានបដិសេធកាលពីថ្ងៃសុក្រថា លោកពុំបានដឹងអ្វីទាំងអស់ អំពីកងទ័ពអាមេរិកាំងនិងវៀតណាមខាងត្បូង ដែលបានធ្វើចលនាចូលមកក្នុងទឹកដីកម្ពុជា, ដូចដែលលោកប្រធានាធិបតីនិចសុនបានផ្សាយ (...) ។ លោកវរសេនិយទោ អំ-រ៉ុង នៅក្នុងឱកាសប្រជុំហ្វឹងមួយ បានធ្វើសេចក្ដីបញ្ជាក់អះអាងថា រដ្ឋាភិបាលកម្ពុជាពុំបានទទួលពត៌មានអ្វីទាំងអស់ អំពីចលនាសម្ព័ន្ធមិត្ត ដែលធ្វើដំណើរចូលមកក្នុងទឹកដីប្រទេសកម្ពុជា ពីព្រំប្រទល់វៀតណាមខាងត្បូង» ។

ត្រង់ចំណុចនេះ សម្ដេចក៏បានសរសេរជួសពីលើដោយអក្សរបារាំងដ៏ល្អខ្ទង់របស់លោក «របបនៃពួករដ្ឋប្រហារ ៖ ត្រូវមាក់ងាយដោយពួកចៅហ្វាយនាយរបស់ពួកវា ដែលបានចូលលុកលុយប្រទេសកម្ពុជាពិតមែន កាលពីថ្ងៃទី១ ឧសភា ឆ្នាំ១៩៧០» ន.សីហនុ ។

ក៏ប៉ុន្តែប្រការដែលលោកឧត្ដមសេនិយលន់-នល់ មិនបានដឹងអំពីការលុកលុយនៃកងទ័ពអាមេរិកាំង-យួនខាងត្បូង ចូលមកក្នុងប្រទេសកម្ពុជា នៅថ្ងៃទី១ ឧសភា ១៩៧០ គឺជាសក្ខីភាពដែលបង្ហាញថា លោកពុំបានលក់ជាតិរបស់លោ

កឲ្យអាមេរិកាំង ដូចការមួលបង្កាច់របស់ស្តេចសីហនុនោះឡើយ ។ ហើយលោកឧត្តមសេនិយលន់-នល់ ក៏រឹតតែមិនបានដឹងថែមទៅទៀតថា ការក្បត់អព្យាក្រឹត្យភាពនៃប្រទេសកម្ពុជា, ការយកភ្លើងសង្គ្រាមទៅដុតផ្ទះខ្លួនឯង, ការអនុញ្ញាតឲ្យទ័ពអាមេរិកាំង-យួនខាងត្បូងបំពារបំពានបូរណភាពទឹកដី គឺស្តេចសីហនុខ្លួនឯងជាអ្នកបានធ្វើ នៅក្នុងសេចក្តីព្រមព្រៀងសម្ងាត់មួយនៅភ្នំពេញ ខែមករា ឆ្នាំ១៩៦៨ ដែលមានចុះហត្ថលេខារបស់សីហនុ, ស៊ឹន-សាន និង Chester Bowles ។



លោកវរសេនិយទោ អំ-រ៉ុង កំពុងបកប្រែឲ្យពួកអ្នកកាសែតសួរចម្លើយយៀកកុងម្នាក់កាលពីថ្ងៃទី២៩ ឧសភា ១៩៧០

សូមអានអត្ថបទឯកសារប្រវត្តិសាស្ត្រមួយរបស់លោក Milton Osborne ៖ «ដំណើរដ៏យឺតយ៉ាវនៃការដាក់ចំណងទូតឡើងវិញជាមួយនឹងសហរដ្ឋអាមេរិក បានធ្វើឡើងតាមរយៈទស្សនកិច្ចរបស់ Jacqueline Kennedy, ភរិយាមេម៉ាយរបស់លោកអតីតប្រធានាធិបតី, នៅខែតុលា១៩៦៧ (សម័យរដ្ឋការយ៉ុនសុន) ។ នេះជារឿងសំណើចចំអកនៃព្រេងវាសនា... ជាដំណើរនយោបាយក្រឡិចក្រឡុចពុតត្បុត ទាំងខាងខ្មែរនិងទាំងខាងអាមេរិកាំង ។ សីហនុដែលបានសំដែងសេចក្តីត្រេកអរសប្បាយហោរកញ្ច្រៀវ កាលពេលដែលប្តីលោកស្រី Jacqueline Kennedy ស្លាប់... ស្រាប់តែឥឡូវនេះ បែរជាមកទទួលលោកស្រីដោយសេចក្តីគួរសមក្រៃលែង ព្រមទាំងផ្តល់កិត្តិយសអធិកអធមដល់លោកស្រីថែមទៀតផង ។ ខាងរដ្ឋាភិបាលអាមេរិកាំងទៀតសោត ក៏សុខចិត្តបិទភ្នែកបំភ្លេចរឿងកំហឹងរបស់សីហនុ កាលពីឆ្នាំ១៩៦៣ (ទាត់ជំនួយអាមេរិកាំង) ក្នុងប្រការស្វែងរកផលប្រយោជន៍វែងឆ្ងាយខាងផ្លូវយុទ្ធសាស្ត្រ ។ បើទោះមានលក្ខណៈសំបកក្រៅត្រឹមតែជានិមិត្តរូបក្តី តែជោគជ័យនៃទស្សនកិច្ចនេះ បានផ្តល់ឱកាសឲ្យមានទស្សនកិច្ចថ្មីមួយទៀត ប្រកបដោយទម្ងន់នយោបាយដ៏កំភួនរបស់លោក Chester Bowles

ដែលមានឋានៈជាអគ្គរដ្ឋទូតអាមេរិកាំងប្រចាំនៅប្រទេសឥណ្ឌា, នៅរយៈពេល២ខែបន្ទាប់មក គឺក្នុងខែមករា១៩៦៨ ។ នៅក្នុងឱកាសទស្សនកិច្ចលើកនេះ លោកសឺន-សាន រដ្ឋមន្ត្រីទី១របស់សីហនុបានបញ្ជាក់ច្បាស់ណាស់ អំពីចំណងស្រេកឃ្លាននៃប្រទេសកម្ពុជា ក្នុងប្រការដាក់ចំណងទូតឡើងវិញជាមួយនឹងសហរដ្ឋអាមេរិក... ការរឹតចំណងមេត្រីមួយដែលចុងចប់ទៅ បានប្រព្រឹត្តឡើងនៅចុងឆ្នាំដដែលនេះ ។ ប៉ុន្តែរឿងដែលមានមូលដ្ឋានសំខាន់មែនទែនក្នុងឱកាសទស្សនកិច្ចរបស់លោក Bowles នេះ គឺការផ្លាស់ប្តូរគោលជំហរទាំងស្រុងរបស់សីហនុដែលបានបង្កើតឲ្យមានផលវិបាកភ្លាមៗផង និងវែងឆ្ងាយផង (ខាងផ្នែកសន្តិសុខអាយុជីវិត) ។ ដោយទទួលស្គាល់មិនចំពោះថា វៀតណាមខាងជើងបានយកទឹកដីកម្ពុជា ធ្វើជាឈ្នាន់មែនទែន, សីហនុបានថ្លែងប្រាប់លោក Bowles ថា ទ្រង់មិនធ្វើការជំទាស់ដល់កងទ័ពអាមេរិកាំង ដែលឆ្លងកាត់ទឹកដីកម្ពុជាទេ ល្អីកណាបើពួកគេកំពុងតែធ្វើការប្រដេញតាមខ្មាំងសត្រូវយ៉ាងប្រផាប់ប្រភឹង ។ ការទទួលយលក្ខ័ណនេះហើយ ដែលជាមូលដ្ឋាននៅថ្ងៃក្រោយមក សំរាប់ដាក់ចំណងទូតឡើងវិញរវាងប្រទេសទាំងពីរ ។ ក្នុងប្រការសង្គ្រាមជើងគោក ដែលប្រព្រឹត្តទៅយ៉ាងពុះពោរនៅវៀតណាម កងទ័ពអាមេរិកាំងលើកនេះ មានប្រៀបយ៉ាងច្រើនជាងមុនទៅលើកម្លាំងសត្រូវ ដោយអាចជំរុញពួកកងទ័ពកុម្មុយនិស្តឲ្យរត់ចូលយ៉ាងជ្រៅ ទៅក្នុងទីជំរករបស់ខ្លួននៅក្នុងដែនដីកម្ពុជា ។ គឺជាវាសនាកម្មអាក្រក់(របស់កម្ពុជា) ដោយមិនរាប់អំពីសេចក្តីបដិសេធជារឿយៗរបស់ Henry Kissinger, ទីក្រុងវ៉ាស៊ិនតោនក៏បានយកសេចក្តីអនុញ្ញាតរបស់ស្តេចសីហនុ ឲ្យដេញតាមចាប់ខ្មាំងសត្រូវ ក្នុងប្រការប្រផាប់ប្រភឹង (the principle of hot pursuit) យកមករិតមួលធ្វើជាលេស ដើម្បីធ្វើការទម្លាក់គ្រាប់បែកយ៉ាងសំបើមមហិមាទៅលើប្រទេសកម្ពុជា ដែលបណ្តាលឲ្យមានការខូចខាតដ៏ធំធេងខាងផ្នែកសម្ភារៈ និងការបាត់បង់ជីវិតយ៉ាងច្រើនជាអតិមរិមា...» (Sihanouk- Prince of light - Prince of Darkness, University of Hawaii Press, p.195-196) ។

⌘

★★★យោងតាមអត្ថបទខាងលើ សីហនុមាន«ចង្កូលដៃទិព្វ»ទាំងសង្ខាង ក៏ប៉ុន្តែទ្រង់បានចង្កូលឲ្យស្លាប់តែប្រជាជាតិរបស់ខ្លួនឯង (!!)

គួរកត់សម្គាល់ទៀតថា អាមេរិកាំងមិនចាំបាច់រឹតមួលស្តេចសីហនុហួសហេតុពេកទេ... ពីព្រោះនៅដើមឆ្នាំ១៩៦៩ គឺសីហនុខ្លួនឯងជាអ្នកបានយកផែនទីសម្ងាត់របស់កងយោធាខ្មែរ ដែលបង្ហាញអំពីទីតាំងជំរំយៀកកុង នៅព្រំប្រទល់ខាងកើត ទៅបោះពុម្ពផ្សាយជាសាធារណៈ (!!) នេះមិនគឺជាសញ្ញាហៅអាមេរិកាំងឲ្យចូលមកទម្លាក់គ្រាប់បែកនៅលើក្បាលជនជាតិខ្មែរទេឬ ? ស្តេចសីហនុបានចោទឧត្តមសេនិយលន់-នល់ ថាជាស្វាររបស់អាមេរិកាំង តែខ្លួនឯងជាស្វាររបស់យៀក

កុង...។ គ្រាន់តែសីហនុលើកផែនទីដែលបង្ហាញអំពីទីតាំងយៀកកុងនៅក្នុងដី



សម្តេចសីហនុកំពុងបង្ហាញទីតាំងកងទ័ពយៀកកុងនៅក្នុងខេត្តរតនគិរី
ដល់ពួកអ្នកកាសែត (ថ្ងៃទី១៧ ឧសភា ១៩៦៩)

ខ្មែរ ឲ្យទៅជាចំណីរបស់សារពត៌មានអន្តរជាតិកាលណា ពួកយៀកកុងក៏បានរត់ប្រសេចប្រសាចចូលទៅក្នុងដីខ្មែរយ៉ាងជ្រៅ (ទាល់តែផុតពីគំនូសឆ្នូត) ហើយជំរុញឲ្យប្រជារាស្ត្រខ្មែរតាមព្រំប្រទល់ ទទួលរងគ្រោះនឹងគ្រាប់បែកអាមេរិកាំងជំនួសពួកវាវិញ ។

នៅពេលដែលសម្តេចសីហនុបានភៀសខ្លួន (ដោយគ្មាននរណាដេញ) ទៅដល់ប៉េកាំង... ទ្រង់ក៏បានបង្កើតរដ្ឋាភិបាលយៀកកុងមួយជាមួយសម្តេចប៉ែន-នុតជារដ្ឋមន្ត្រីទី១ ។ តទៅនេះគឺជាអត្ថបទដកស្រង់ពីកម្មវិធីរដ្ឋាភិបាលរបស់ស្តេច (ស្វា)យៀកកុងនៅប៉េកាំង ថ្ងៃទី៥ ឧសភា ១៩៧០... ទាក់ទងនឹងនយោបាយក្រៅប្រទេស ៖

«២- នយោបាយការបរទេសនៃកម្ពុជា នៅថ្ងៃនេះនិងតទៅថ្ងៃមុខនៅតែដដែល គឺជានយោបាយនៃឯករាជ្យជាតិ នៃសន្តិភាព, អព្យាក្រឹត្យមិនចូលបក្សខាងណា ជានយោបាយសាមគ្គីភាពនិងមិត្តភាព ជាមួយគ្រប់ប្រជាជាតិនិងរដ្ឋាភិបាលទាំងអស់ ដែលស្រឡាញ់សន្តិភាពនិងយុត្តិធម៌ ។

នៅក្នុងគោលគំនិតនេះ រាជរដ្ឋាភិបាលថ្មីរួបរួមជាតិកម្ពុជា ក្រោមសញ្ញាហ្វ៊ុងសូមប្រកាសនូវសេចក្តីគោរពជាដាច់ខាត ចំពោះគ្រប់សន្ធិសញ្ញានិងសេចក្តីព្រមព្រៀងជាអន្តរជាតិ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខារហូតដល់ថ្ងៃទី១៨មិនា

១៩៧០...» ។

★★★ យោងតាមអត្ថបទខាងលើនេះ សម្ដេចសីហនុនៅប៉េកាំង (១៩៧០) នៅតែគោរពសន្ធិសញ្ញាពីរដ៏សំខាន់ជាងគេ ដែលទ្រង់បានចុះហត្ថលេខា នៅក្នុងអតីតកាល ៖

ទី១- សន្ធិសញ្ញាដើមដំបូងជាមួយប្រទេសបារាំងក្នុងឆ្នាំ១៩៤៩ ដោយស្ដេចខ្មែរសុខចិត្តយល់ព្រមលះបង់ទឹកដីកម្ពុជាក្រោមទៅយួន (!!)

ទី២- សន្ធិសញ្ញាជាមួយសហរដ្ឋអាមេរិកនៅឆ្នាំ១៩៦៨ ដោយមានការព្រមព្រៀងរបស់ប្រមុខរដ្ឋខ្មែរ ឲ្យអាមេរិកាំងទម្លាក់គ្រាប់បែកទៅលើទឹកដីប្រទេសកម្ពុជា ។

បើគេយល់ថា ស្ដេចសីហនុមានដៃឆ្វេងអនុញ្ញាតឲ្យយៀកកុងមកតាំងនៅក្នុងដីកម្ពុជាផង... ចំណែកដៃស្ដាំប្រទាញអាមេរិកាំងឲ្យមកទម្លាក់គ្រាប់បែកនៅត្រង់«តំបន់ឆ្លូត» គឺតំបន់ទីតាំងរបស់យៀកកុងផង នោះស្ដេចសីហនុគ្រាន់តែជាទ្រនាប់បាតដៃរបស់វៀតណាមទាំងពីរ ទាំងខាងត្បូងទាំងខាងជើង ដើម្បីធ្វើប្រទេសកម្ពុជាធ្លាក់ទៅក្នុងមហាវិនាសកម្មខ្មោចផ្សារអន្តរាយហៅមិនឮ ឲ្យក្លាយទៅជាផេះផង់ ជាសំបុកឥតសត្វ... ឲ្យទៅជាកម្ពុជាដែលឥតមានខ្មែរ ដែលរបេះធ្លាក់ចូលទៅក្នុងរណ្ដៅមរណៈនៃសហព័ន្ធឥណ្ឌូចិន-វៀតណាម ដូចផ្លែឈើទុំ ។

⌘

ខ្ញុំសូមបង្ហាញឯកសារមួយទៀតរបស់លោក Pierre Marx (សាស្ត្រាចារ្យបារាំងម្នាក់ដែលនៅគណបក្សរបស់ឧត្តមសេនិយដឺហ្គោល) ដែលបញ្ជាក់អំពីភក្ដីភាពស្នេហាជាតិរបស់ឧត្តមសេនិយលន់-នល់ ដែលភ័យព្រួយអំពីការរាលដាលនៃសង្គ្រាមអាមេរិកាំង-យួនចូលក្នុងដីខ្មែរ នៅក្នុងឆ្នាំ១៩៦៩ ។ ឯកសារដដែលនេះបានបង្ហាញពីស្ដេចសីហនុ ជាសត្វស្វារបស់អ្នកម្នាងម៉ូនិចសុទ្ធសាធ ស្ដេចឆ្កួតបល់បាយ លែងដឹងខ្យល់បក់មកពីទិសខាងណា... ស្ដេចឆ្កួតនឹងមហោស្រព នឹកឃើញតែមួយមុខ ថាខ្លួនជាតារាភាពយន្តអន្តរជាតិដូច Peter O'toole ឬក៏ជាអ្នកដឹកនាំរឿងល្បីល្បាញដូច Marcel Camus ៖

«...នៅថ្ងៃទី១៦ កុម្ភៈ ១៩៧០, មុននឹងចាកចេញពីទីក្រុងប៉ារីសទៅប្រទេសកម្ពុជា ឧត្តមសេនិយលន់-នល់បាននិយាយប្រាប់ខ្ញុំដោយពាក្យដូច្នេះថា «សភាពការណ៍សព្វថ្ងៃមានលក្ខណៈធ្ងន់ធ្ងរមែនទែន ។ ពួកខាងយោធា (ខ្មែរ) **មិនអាចអនុញ្ញាតឲ្យពួកយៀកកុងរុករុលចូលមកក្នុងដីខ្មែរមិនចេះឈប់ឈរដូច្នេះទេ**, ពួកនេះបានក្បត់កិច្ចសន្យារបស់ខ្លួន ដែលបញ្ជាក់ថា មិនដើរទៅណាឲ្យហួសពីកន្លែងជំរកទីតាំងរបស់ពួកខ្លួននោះឡើយ ។ នៅខេត្តស្វាយរៀង កងទ័ពរបស់យើងលែងបញ្ជាអ្វីបានទៀតទៅហើយនៅលើទឹកដីរបស់ខ្លួន ។ កាលណាមានក្បួនដំណើរយៀកកុងមួយមកដល់ ពួកគេតែងរាំងផ្លូវនៃទាហានរបស់យើង ។ នេះពុំ

មែនជាវត្ថុមានមួយដែលគេមើលមិនឃើញឬដែលមានលក្ខណៈសុភាពរាបសារនោះទេ តែគឺជាការកាន់កាប់ទឹកដីត្រង់ៗតែម្តង ។ ពួកយៀកកុងបានដើរប្រមូលស្រូវអង្ករព្រមទាំងសត្វពាហនៈ ពីប្រជាកសិកររបស់យើង ។ តើពួកអស់លោកបារាំងយល់យ៉ាងណាដែរ... ឧបមាបើជនជាតិអាល្លឺម៉ង់មកដាក់មូលដ្ឋានយោធានៅ Alsace ហើយលុកលុយចូលក្នុងខេត្ត Lorraine បន្តិចម្តងៗ ? ម៉្យាងទៀតពួកអាមេរិកាំងនឹងច្បាស់ជាចូលមកទម្លាក់គ្រាប់បែកលើយើង, ចំណែកកងទ័ពវៀតណាមខាងត្បូង នឹងច្បាស់ជាចូលមកធ្វើអន្តរាគមន៍មួយជាន់ទៀត ។ គឺជាការរមៀលចូល (នៃកម្ពុជា) ទៅក្នុងភ្លើងសង្គ្រាមដោយចៀសមិនផុត ។ ខ្ញុំសូមជំរាបលោកតាមត្រង់ទៅចុះ បើសម្តេចព្រះប្រមុខរដ្ឋមិនយាងត្រឡប់ទៅភ្នំពេញវិញជាប្រញាប់នោះទេ អ្វីៗក៏មិនអាចកែកុនបានទៀតឡើយ» ។ («Cambodge du Silence», par Sam Prasith et Pierre Max- page 115) ។

★★★ នៅថ្ងៃទី៨មិនា១៩៧០, បានផ្ទុះបាតុកម្មដេញយួនពីសំណាក់ប្រជាពលរដ្ឋខ្មែរ (ប្រកបដោយវត្តមានទាហាន, ពួករាជការស៊ីវិល, ព្រះសង្ឃ, អ្នកស្រុក) នៅខេត្តស្វាយរៀង, រៀបចំធ្វើឡើងដោយឧត្តមសេនិយលន់-នល់ ក្រោមបញ្ជារបស់សម្តេចសីហនុព្រះប្រមុខរដ្ឋ ។ តើនៅក្នុងពេលនោះ ស្តេចខ្មែរកំពុងតែធ្វើអ្វីដែរនៅទីក្រុងប៉ារីស ? នេះជាឯកសារប្រវត្តិសាស្ត្រមួយទៀតរបស់លោក Pterre Max ៖

«...តើនរណាគេជាសីហនុ ? ខ្ញុំខំប្រឹងស្វែងរកយល់ ជាពិសេសខំប្រឹងរកយល់អំពីបុគ្គលិកលក្ខណៈរបស់ទ្រង់ ។ នៅថ្ងៃទី៨មិនា១៩៧០, សម្តេចសីហនុបានកោះហៅខ្ញុំឲ្យទៅជប់លៀង ជាមួយនឹងមិត្តភក្តិបារាំងបីបួននាក់ទៀត នៅដំណាក់របស់ទ្រង់នៅទីក្រុងប៉ារីស ៖ គឺ Marcel Camus អ្នកដឹកនាំរឿងនៃភាពយន្ត Orfeu Négro និងភរិយាដ៏ស្រស់របស់លោកជាតិប្រេស៊ីល Lourdes de Oliveira; François Chalet អ្នកសារពត៌មានដ៏ល្បីល្បាញជាមួយនិងភរិយាដ៏ផ្អែមពិសាររបស់លោកជាតិវៀតណាម ។ ហើយក៏មានម៉ូនិកផងដែរ ៖ អ្នកម្នាងម៉ូនិកព្រះម្ចាស់ក្សត្រីម៉ូនិក ដែលមានសម្រស់ក្រៃលែង, នឹងធួន, សុភាពរាបសារគួរឲ្យស្រឡាញ់, ភរិយារបស់សីហនុ ដែលបានឈ្នះលើស្រីដទៃទៀតទាំងអស់, ស្រីតែមួយដែលជាកំពូលដួងចិត្តរបស់ទ្រង់...។

«ខ្ញុំបានទៅដល់ដំណាក់របស់ទ្រង់មុនគេ, នៅពេលនោះមានតែម៉ូនិក, សីហនុ ហើយនិងខ្ញុំតែប៉ុណ្ណោះ ។ យើងបាននិយាយសន្ទនាគ្នាយ៉ាងយូរ ។ សីហនុក៏បានយល់ព្រមពីគំរោងការណ៍របស់ខ្ញុំ... ទ្រង់បានស្នើឲ្យខ្ញុំត្រឡប់ទៅប្រទេសកម្ពុជាវិញ ដើម្បីជួយបំពេញមុខការរបស់ទ្រង់ ។ ក៏ប៉ុន្តែ...

«ក៏ប៉ុន្តែមានរឿងតែមួយគត់ដែលខ្ញុំមិនហ៊ានទូលប្រាប់សម្តេច, គឺការពិត ។ គឺអ្វីៗដែលឧត្តមសេនិយលន់-នល់ នាយករដ្ឋមន្ត្រីបានថ្លែងប្រាប់ខ្ញុំកាលពីថ្ងៃទី

១៦កុម្ភៈ១៩៧០, មុនដែលលោកធ្វើដំណើរចាកចេញទៅទីក្រុងភ្នំពេញ...គឺថាបើសម្ដេចមិនយាងត្រឡប់យ៉ាងប្រញាប់ទៅទីក្រុងភ្នំពេញ ដើម្បីក្ដោបក្ដាប់សភាពការណ៍ឡើងវិញទេនោះ «អ្វីៗក៏លែងអាចកែកុនបានទៀតហើយ» ។

«...សម្ដេច សូមទ្រង់យាងត្រឡប់ទៅភ្នំពេញវិញ...សូមព្រះអង្គយាងទៅកាន់កាប់កិច្ចការរដ្ឋនិងកងទ័ពឡើងវិញ... បើពុំនោះសោតនឹងមានអ្នកដទៃធ្វើចំណាត់ការជួសព្រះអង្គជាមិនខាន...» ។

«គួរជ្រាបថា សីហនុមិនចូលចិត្តស្ដាប់ការពិតបែបដូចនេះទេ ។ តែក្នុងមួយក្រឡាប់ភ្នែកសោះ ទ្រង់លោតពីបញ្ហាដ៏ធ្ងន់ធ្ងរ ចូលទៅក្នុងរឿងបញ្ហាកំប្លុកកំប្លែង ។ ទ្រង់ព្រះសំរួលច្រើនពេកណាស់... ទ្រង់ស្ដាប់តែខ្លួនឯង គ្មានស្ដាប់នរណាទៀតទេ, វៀរលែងតែកាលណាគេនិយាយអំពីរឿងភាពយន្ត ។ គឺរឿងភាពយន្តនេះហើយ ជាបញ្ហាសំខាន់នៅក្នុងពេលជប់លៀង ។

– សភាពការណ៍នៅក្នុងប្រទេសខ្ញុំ... ជាការពិតវាធ្ងន់ធ្ងរមែនទែន ។ ពួកវៀតណាមគឺជាសត្រូវស្បួរពូជរបស់យើង... ពួកយៀកកុងអស់ទាំងនេះ ខ្ញុំត្រូវតែសើចញញឹមដាក់ពីខាងមុខ ប៉ុន្តែខ្ញុំទាត់ពួកគេពីខាងក្រោយ ។ ខ្ញុំត្រូវធ្វើដំណើរទស្សនកិច្ចទៅទីក្រុងមូស្គូ, ប៉េកាំង, ហាណូយ...។ ខ្ញុំគ្រាន់តែនិយាយជាមួយពួកគេក៏គ្រប់គ្រាន់ណាស់ទៅហើយ គឺសុទ្ធសឹងតែជាមិត្តភក្ដិរបស់ខ្ញុំទាំងអស់...កុស្សីគ្គីន, ជូ-អេនឡាយ, ផាំ-យ៉ាំងដុង ។ ពួករុស្ស៊ី, ពួកចិន នឹងបង្ខំពួកវៀតណាមកុំឲ្យរុលចូលក្នុងទឹកដីខ្មែរ គឺឲ្យនៅសម្ងំតែក្នុងកន្លែងទីតាំងរបស់ខ្លួននោះបានហើយ..

«ទោះជាយ៉ាងណាក្ដី គ្មាននរណាអាចឆ្លើយតបចំពោះព្រះអង្គអំពីបញ្ហានេះទេ ដោយសារតែទ្រង់បានបង្វែទៅរឿងជីវិតពិសោធន៍របស់ទ្រង់ ក្នុងបញ្ហាភាពយន្តរួចទៅហើយ ។ នៅពេលនោះ កុំឲ្យតែមានវាចារបស់ទ្រង់មួយម៉ាត់ទាក់ទងនឹងបញ្ហានយោបាយ...» («Cambodge du Silence» Ibidem- p.113-114) ។

⌘

★★★ តទៅនេះជាឯកសាររបស់ខ្ញុំផ្ទាល់ (ស្រង់ចេញពីសៀវភៅ «Cambodge - Le Chemin de l'Apocalypse» ដែលបង្ហាញអំពីអាកប្បកិរិយាដ៏ចម្លែក ជាមនុស្សឆ្កួតនឹងកាមរាគ) របស់ស្ដេចសីហនុ នៅក្នុងខែវិច្ឆិកា-ធ្នូ ឆ្នាំ១៩៦៩, ២ខែមុនព្រះអង្គបោលរត់ចោលស្រុកទៅចូលយៀកកុង !!

«...សារជាថ្មី ចូលដល់ខែធ្នូ១៩៦៩, សម្ដេចព្រះប្រមុខរដ្ឋមានបុកពារអាកប្បកិរិយាដូចមនុស្សស្លាប់ (ពួនសម្ងំស្ងួនស្ងៀមឈឹង) ។ ពួកអ្នកភ្នំពេញបាននិយាយចំអកដល់ទ្រង់គ្រប់ទីកន្លែង ពីតណ្ហាងប់ងល់ផ្ដេកផ្ដួលមោហាបាំងជញ្ជាំងបិទ ចំពោះស្នំចុងក្រោយរបស់ទ្រង់ នាងម៉ូនិក-អ៊ីស៊ី ដែលមានអាយុតិចជាងព្រះអង្គ១៥ឆ្នាំ ។ ខ្ញុំនិយាយពីតណ្ហាមុខខ្លាញ់នេះ មិនមែនសំដៅទៅលើផ្លូវភេទប៉ុន្មានទេ ។ ប៉ុន្តែសម្ដេចសីហនុហាក់ដូចជាមិនអាចមានជីវិតរស់នៅបាន បើគ្មានវត្តមានរបស់ស្រី

ម្នាក់នេះ ។ គឺជាស្នេហាជាប់ចិត្តជាប់ថ្លើមមួយ ដែលទំនងដូចជាការយលសប្តិមមើមមាយឬការត្រូវសណ្តំដោយមន្តអាគម គឺជាកាមរាគប្រកបដោយលក្ខណៈបិសាច ដែលមិនអាចឲ្យមានវត្តមាននៃរដ្ឋកម្ពុជា ។ ព្រះនាងដើរតាមទ្រង់គ្រប់ទីកន្លែង ពុំនោះសោតគឺទ្រង់ដើរតាមព្រះនាងគ្រប់ទីកន្លែង ។ បើកាលណាគ្មានព្រះនាងនៅក្បែរទេ ជីវិតរបស់ព្រះអង្គហាក់ដូចជាគ្មានរសជាតិ ឬគ្មានខ្លឹមសារ ។ ប្រៀបបាននឹងសត្វហ៊ីងពីរអង្គដែលឆ្លៀតឱកាសជាន់គ្នាក្នុងរដូវវស្សា...

សម្តេចព្រះប្រមុខរដ្ឋនិងស្រីសម្លាញ់របស់ទ្រង់ជាផ្លូវការ បានលេចចេញនិងលិបចូលមិនចេះស្វាង ពីក្រោយវាំងននធំ«មំសំសិល្ប:» (អានថា «មាំងសាំងសិល្ប:» ឬសិល្ប:សាច់– Derrière l'écran de la libido) ។ ជាឧទាហរណ៍ នៅក្នុងខែកន្លងទៅ គឺវិច្ឆិកា១៩៦៩, ស្តេចសីហនុហើយនិងអ្នកម្នាងម៉ូនិក ក្នុងនាមជាមហាតារាភាពយន្តអន្តរជាតិ ទើបតែបានទទួលរង្វាន់កិត្តិយសទាំងពីរនាក់នូវតុរង្វាន់លេខ១ នៅក្នុងឱកាសបុណ្យ ហ្វេសទីវ៉ាល់ ភាពយន្តអន្តរជាតិ ដែលបានធ្វើឡើងជាលើកទី២នៅទីក្រុងភ្នំពេញ ហើយដែលសម្តេចខ្លួនឯងបានរៀបចំយ៉ាងអធិកអធមនិងហ្មត់ចត់ អស់រយៈពេលមួយខែពេញ ដោយបារយកប្រាក់សេសសល់ទាំងប៉ុន្មានពីឃ្លាំងថវិកានៃរដ្ឋកម្ពុជា ។ បានចូលរួមបរួមក្នុងបុណ្យហ្វេសទីវ៉ាល់នេះ មានស្រីតួកុនចិនមកពីហុងកុង និងស្រីតួកុនយួនមកពីហាណូយ ។ បានត្រូវអញ្ជើញឲ្យមកចូលរួមបរួមផងដែរ គឺពួកអ្នកកាសែតបរទេសលិទ្ធបាតជើង, ពួកអ្នកបញ្ចើចបញ្ចើរតួយ៉ាងដូចជា Jean Barré, Gérard Brissé, Pierre Fuch ឬក៏អ្នកនិពន្ធពុករលួយ ដូចជាអ្នកស្រី Han Suyin ។

ពួកបញ្ញវ័ន្តក្លែងក្លាយអស់ទាំងនេះ ដែលបានលើកដម្កើងអំពើឆ្កួតលីលារបស់ស្តេចសីហនុ ហើយដែលធ្លាប់បានអួតអាងថា ពួកខ្លួនមានសម្បជញ្ញៈល្អខាងផ្នែកសង្គមនិយម ពួកគេឥតមានសេចក្តីអៀនខ្មាស់ទាល់តែសោះ ក្នុងប្រការក្រសាវប្រមូលនិងហុតឈាមអង្គាមឆ្អឹង ទៅលើភាពក្រីក្ររហេមរហាមចុងក្រោយនៃប្រជាពលរដ្ឋខ្មែរ ។ យើងគួរគិតស្មានបន្តិចទៅមើល ឧបមាបើស្តេច Louis XIV បានសំរេចលោតទៅក្នុងឆាកមហោស្រព ហើយបណ្តេញ Molière ឲ្យចេញទៅក្រៅសៃរៀន តើក្រុមនិពន្ធដូចជា Boileau និង Racine ពួកគេយល់យ៉ាងណាដែរ ? ។

«ជាការច្បាស់ណាស់ សម្តេចសីហនុមានទំនងដូចជាហត់នឿយជាខ្លាំង បន្ទាប់ពីបានបញ្ចេញក្បាច់ស្នេហាឥតកំណត់ព្រំដែនរបស់ទ្រង់ ។ គឺវាហាក់ដូចជាថា សម្តេចហើយនិងអ្នកម្នាងម៉ូនិក ទើបនឹងបានក្រេបជញ្ជក់ទឹកដមស្នេហាចុងក្រោយមុនពេលស្លាប់ នៅលើកោះចុងប៉ូចដាច់ស្រយាលមួយនៃពិភពលោកដូច្នោះឯង ។ បើទោះជាមានកងកម្លាំងបរទេស ពួកយៀកកុងនិងយៀកណាមខាងជើងចូលមកឡោមព័ទ្ធដល់មាត់ទ្វារព្រះរាជវាំងទៅហើយក្តី រឿងទាំងនេះវាហាក់

ដូចជាគ្មានសារៈអ្វីសំខាន់ទាល់តែសោះ ឬពុំដូច្នោះទេ ពួកយៀកកុងទាំងនេះប្រែក្លាយទៅជារបាំងការពារ នូវសេចក្តីស្នេហាដាច់ខ្យល់ រវាងសង្សារថ្មើមប្រមាត់ទាំងពីរនាក់នេះទៅវិញ ។ គឺជាការច្បាស់ណាស់ សត្វតិរច្ឆានសីហនុមានការព្រួយបារម្ភជាពន់ពេកក្រែងអ្នកផងឆក់អូសយកស្រីឆោមឆាយរបស់ទ្រង់បាត់ទៅ ។ ក្នុងប៉ុន្មានខែចុងក្រោយនេះ ពួកគេទាំងពីរចេះតែសម្លឹងសម្លក់ដាក់គ្នា ចោលក្រសែភ្នែកងប់ងល់ឈ្លក់វង្វេង ធ្វើមើលតែ «បុប្ផបាក់ទង-កន្លង់បាក់ស្លាប» ។ ពួកគេឃើញតែដើរតួជាមួយគ្នាមិនចេះឈប់ឈរ, ពឹតតែច្រៀងចូលគ្នានិងថើបគ្នាជាសាធារណៈ ធ្វើមើលតែជាការថ្នាក់ថ្នមបបោសអង្អែលរវាងគូសាហាយស្មន់ ។ ប្រហែលមកពីប្រការនេះទេដឹង បានជាសត្វតិរច្ឆានខ្លងពីរ ឬសត្វឃោគីឃោគា បន្ទាប់ពីហូបទឹកក្រុដ្ឋស្នេហាឆ្អែតឆ្អន់រួចកាលណា ក៏បានដេកដួលរលំលើគ្នា ដើម្បីសំរាកនៅក្នុងខែធ្នូ១៩៦៩នេះ ។ មិនគឺដោយសារព្រះអង្គទាំងពីរខំប្រឹងសន្សំប្រមូលកម្លាំងធាតុឡើងវិញទេឬ ? ទើបបានពួកគេចូលសម្ងំស្ងៀមឈឹងហាក់ដូចស្លាប់ ។ សម្តេចជាអម្ចាស់បានយាងទៅដល់ឋានភូរជង្គលីលារួចទៅហើយ ។ ព្រះអង្គអស់កំសួលរលីងហើយ ។ វិញ្ញាណរបស់ទ្រង់លែងឆ្លើយតបតចំពោះរឿងអ្វីទាំងអស់ ។ **Le Manitoba ne répond plus** !» ។៚